hepatitis australia



# សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក៖

## ការរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ឬជំងឺរលាកថ្លើមប្រភេទ C

នៅប្រទេសអូស្រ្តាលី មនុស្សដែលរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B (hep B) និងជំងឺរលាកថ្លើមប្រភេទ C (hep C) មានសិទ្ធិការពារពួកគេពីការរើសអើង។ មនុស្សដែលរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ឬ C ក៏មានទំនួលខុសត្រូវដើម្បីការពារសុខភាពសាធារណៈផងដែរ។

### អ្នកមានសិទ្ធិទទួលបានការថែទាំសុខភាព ប្រកបដោយគុណភាព និងលាក់ការសម្ងាត់

- អ្នកមានសិទ្ធិដើម្បីតវ៉ា ប្រសិនបើអ្នកត្រូវបានគេប្រព្រឹត្តចំពោះអ្នកដោយមិនយុត្តិធម៌ ឬអ្នកមិនសប្បាយចិត្តជាមួយនឹងគុណភាពនៃសេវាកម្ម។
- អ្នកប្រកបវិជ្ជាជីវៈខាងសុខភាពរបស់អ្នកគួរតែប្រមូលតែព័ត៌មានសុខភាពរបស់អ្នក ឬធ្វើតេស្តដោយមានការយល់ព្រមរបស់អ្នកប៉ុណ្ណោះ។[1]
- មានករណីតែពីរបីប៉ុណ្ណោះដែលសេវាកម្មសុខាភិបាលអាចបញ្ចេញព័ត៌មានសុខភាពរបស់អ្នក ដូចជានៅពេលមានហានិភ័យធ្ងន់ធ្ងរដល់ជីវិត សុខភាព ឬសុវត្ថិភាពរបស់អ្នក ឬមនុស្សផ្សេងទៀត ដែលត្រូវបានតម្រូវដោយច្បាប់ ឬកន្លែងដែលមានហានិភ័យសុខភាពសាធារណៈ។[2]

### អ្នកមានសិទ្ធិចំពោះការសម្ងាត់នៅកន្លែងធ្វើការ និងការកែតម្រូវការងារសមហេតុផល

- អ្នកអាចស្នើសុំនិយោជករបស់អ្នកឱ្យធ្វើការកែតម្រូវសមហេតុផល ដូច្នេះអ្នកអាចបំពេញតួនាទីធម្មតារបស់អ្នកបាន។ អ្នកនឹងទំនងបំផុត ត្រូវផ្តល់សំបុត្រពេទ្យ។[3]
- និយោជកមិនអាចប្រាប់មនុស្សដទៃទៀតថាអ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬ C ដោយគ្មានការអនុញ្ញាតរបស់អ្នកឡើយ[4] តែអ្នកគួរតែពិចារណាដោយប្រុងប្រយ័ត្នពីមូលហេតុដែលអ្នកចង់ប្រាប់ពួកគេ។

# អ្នកមានទំនួលខុសត្រូវក្នុងការការពារសុខភាពសាធារណៈ

## ដើម្បីការពារសុខភាពសាធារណៈ មានស្ថានភាពមួយចំនួន ដែលអ្នកត្រូវតែបញ្ចេញថាអ្នកមាន ឬពីមុនមកមានជំងឺរលាកថ្លើម។

អ្នក **មិនអាចបរិច្ចាគឈាម** ឬប្លាស្មាបានទេ ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬរលាកថ្លើមប្រភេទ C ឬពីមុនមកមានជំងឺរលាកថ្លើមប្រភេទ C។[5]

ប្រសិនបើអ្នកកំពុង**ដាក់ពាក្យសុំទិដ្ឋាការ ដើម្បីរស់នៅក្នុងប្រទេសអូស្ត្រាលី** អ្នកគួរតែឆ្លើយសំណួរទាំងអស់ដោយស្មោះត្រង់។ អ្នកត្រូវបានផ្ដល់អនុសាសន៍ឱ្យស្វះស្វែងរកជំនួយពីទីភ្នាក់ងារអន្តោប្រវេសន៍ដែលបានបញ្ជីស្របច្បាប់ មុនពេលដាក់ពាក្យសុំការស្នាក់នៅជាអចិន្ត្រៃយ៍ ឬភាពជាប្រជាពលរដ្ឋ។ នៅក្នុងករណីខ្លះ អ្នកអាចនឹងតម្រូវឱ្យធ្វើតេស្តរកជំងឺរលាកថ្លើម។.

អ្នក **អាចចាំបាច់ត្រូវប្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក** ថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬជំងឺរលាកថ្លើមប្រភេទ C ប្រសិនបើសុខភាពរបស់អ្នកអាចប៉ះពាល់ដល់ការសម្រេចចិត្តពួកគេ ឬលក្ខខណ្ឌនៃការធានារ៉ាប់រងអ្នក។ ប្រសិនបើអ្នកមិនប្រាប់ពួកគេទេ ពួកគេអាចធ្វើឱ្យកិច្ចសន្យារបស់អ្នកទុកជាមោឃៈ ប្រសិនបើអ្នកចាំបាច់ត្រូវ ធ្វើការទាមទារសំណង។[6]

ប្រសិនបើអ្នកជា **សមាជិកនៃកងកម្លាំងការពារអូស្ត្រាលី** (ADF) អ្នកត្រូវតែប្រាប់ ADF។[6]

ប្រសិនបើអ្នកជា **បុគ្គលិកថែទាំសុខភាព អ្នកត្រូវតែគោរពតាមគោលការណ៍ណែនាំថ្នាក់ជាតិ** ស្ដីអំពីការបញ្ចេញព័ត៌មានអំពីវីរុសឆ្លងតាមឈាម៖[7] www1.health.gov.au/internet/main/publishing.nsf/Content/cda-cdna-bloodborne.htm

ប្រសិនបើអ្នកចង់ **បរិច្ចាគសរីរាង្គ ឬមេជីវិតឈ្មោល** អ្នកនឹងត្រូវធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B និងជំងឺរលាកថ្លើមប្រភេទ C។ អ្នកប្រហែលជានៅតែអាចបរិច្ចាគបាន តែនេះនឹងត្រូវបានកំណត់ដោយផ្អែកលើករណីនីមួយៗ។[8]

ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬ C **វាជាជម្រើសរបស់អ្នកថាតើមិត្តភ័ក្តិ និងក្រុមគ្រួសារមួយណាដែលអ្នកប្រាប់** ប៉ុន្តែអ្នកគួរតែពិចារណាប្រាប់មនុស្សដែលអាចនឹងបានប៉ះពាល់នឹងវីរុស ដូច្នេះពួកគេអាចធ្វើតេស្ត ហើយប្រសិនបើចាំបាច់ ត្រូវទទួលការព្យាបាល។ ប្រសិនបើពួកគេមិនបានទទួលរងប៉ះពាល់មេរោគទេ ពួកគេអាចទទួលការចាក់ថ្នាំបង្ការរោគ ដូច្នេះពួកគេមិនអាចកើតជំងឺរលាកថ្លើមប្រភេទ B នៅពេលអនាគត។ ប្រសិនបើអ្នកមានអារម្មណ៍ថាមិនមានអារម្មណ៍ស្រួលក្នុងការប្រាប់អ្នកដទៃដែលអាចរងប៉ះពាល់នឹងមេរោគ អ្នកអាចស្នើសុំវេជ្ជបណ្ឌិតអ្នកប្រាប់ពួកគេឱ្យបានដឹងជាអនាមិក។.

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានលម្អិតបន្ថែមស្ដីពីសិទ្ធិ និងទំនួលខុសត្រូវ របស់អ្នកក្នុងការរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ឬជំងឺរលាកថ្លើមប្រភេទ C សូមចូលមើល hepatitisaustralia.com/your-rights-and-responsibilities ឬហៅទូរស័ព្ទទៅបណ្ដាញទូរស័ព្ទផ្ដល់ព័ត៌មានអំពីជំងឺរលាកថ្លើម លេខ 1800 437 222 ដើម្បីនិយាយទៅកាន់អង្គការសហគមន៍ ជំងឺរលាកថ្លើម នៅក្នុងរដ្ឋ ឬទឹកដីរបស់អ្នក។

hepatitis australia

**1800 437 222**

**hepatitisaustralia.com**




**ឯកសារយោង** **1.** Australian Commission on Safety and Quality in Health Care. (2019). My Healthcare Rights. **2.** ASHM. (n.d.). Guide to Australian HIV Laws and Policies for Healthcare Professionals. **3.** Australian Human Rights Commission. (2012, December 14). A brief guide to the Disability Discrimination Act **4.** Australian Human Rights Commission. (2010). 2010 Workers with Mental Illness: a Practical Guide for Managers - Appendix A: Knowing the Law **5.** Australian Red Cross Blood Service. (n.d.). I had hepatitis - can I donate? **6.** Disability Discrimination Act 1992. (2018, April 19). Australia: Federal Register of Legislation. **7.** Department of Health. (2018, December). Australian National Guidelines for the Management of Healthcare Workers Living with Blood Borne Viruses and Healthcare Workers who Perform Exposure Prone Procedures at Risk of Exposure to Blood Borne Viruses. **8.** NHMRC. (2017). Ethical guidelines on the use of assisted reproductive technology in clinical practice and research



ធនធាននេះត្រូវបានផ្ដល់ជូនសម្រាប់ព័ត៌មានទូទៅប៉ុណ្ណោះ ហើយមិនមានបំណងជំនួសដំបូន្មានផ្នែកច្បាប់ ឬវេជ្ជសាស្ត្រទេ។ យើងសូមលើកទឹកចិត្តឱ្យអ្នកស្វែងរកដំបូន្មានឯករាជ្យ មុនពេលធ្វើការសម្រេចចិត្តណាមួយផ្អែកលើព័ត៌មានដែលបានផ្ដល់ជូននៅទីនេះ។